ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០៣២/១៩ គ.ជ.ប.ជ

# របាយការណ៍បូកសរុប
## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែមករា និងទិសដៅខែកុម្ភៈ ឆ្នាំ២០១៩

## I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីរាជរដ្ឋាភិបាលថៃ បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល ពលរដ្ឋខ្មែរនៅតែបាន និងកំពុងចូលទៅធ្វើការនៅប្រទេសថៃ ដោយខុសច្បាប់ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានិភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌ ពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលា ជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ច ផ្តល់ឯកសារក្លែងក្លាយជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

### ក. ការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការងារបទដ្ឋានច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងឯកសារកិច្ចសហប្រតិបត្តិការកំពុងរៀបចំ និងដំណើរការ

ក.១.១. គោលនយោបាយកំពុងរៀបចំ

- ក្រសួងអប់រំ យុវជន និងកីឡា៖ កំពុងធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារតាមសាលារៀន"។

**ក.១.២.សេចក្តីព្រាងច្បាប់កំពុងរៀបចំ**

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
  - ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

**ក.១.៣.សន្ធិសញ្ញាកំពុងរៀបចំ**

- **ក្រសួងយុត្តិធម៌**
  - បាននិងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បាននិងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**" ។

**ក.១.៤.អនុស្សរណៈកំពុងរៀបចំ**

- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់ រដ្ឋមន្ត្រីលើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្តីពី "**ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី**"

**ក.១.៥.បទដ្ឋានគតិយុត្តកំពុងរៀបចំ**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**៖ ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តល័ក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ**"។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការងារបង្ការ ទប់ស្កាត់

### ខ.១. ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង

**ខ.១.១.ការផ្សព្វផ្សាយដោយផ្ទាល់**

**ខ.១.១.១.ការផ្សព្វផ្សាយតាមរយៈវេទិកា និងកម្មវិធីផ្សេងៗ**

នៅក្នុងខែមករា ឆ្នាំ២០១៩នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោលបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" ដល់សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានសរុបចំនួន **៥៤.៩៧២**លើក មានអ្នកចូលរួមសរុបចំនួន ២៧០.៧៤៨នាក់(ស្រី១១៥.៨០២នាក់)។

# តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | ក្រសួងអប់រំ យុវជន និងកីឡា | | | | | | |
| ២ | ក្រសួង ក.ប.វ | | | | | | |
| ៣ | ក្រសួងកិច្ចការនារី | | | | | | |
| ៤ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៩៦ | ១០.៣២៣ | ៤.៧១៦ | | | |
| | សរុប ក្រសួង ស្ថាប័ន | ៩៦ លើក | ១០.៣២៣ នាក់ | ៤.៧១៦ នាក់ | | | |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៣៨ | ៦៩០ | ៥៤៣ | ៣៦៧ | ១៧.២១៦ | ៨.៥៥៣ |
| ៣ | ខេត្តបាត់ដំបង | ៤៨៣ | ២៨.៧៥៩ | ១៥.៤៧០ | ២២៤ | ១០.៣៨៤ | ៥.២៨៤ |
| ៤ | ខេត្តពោធិ៍សាត់ | | | | ៦០៥ | ៣៧.១៤៤ | ២១.០៩១ |
| ៥ | ខេត្តសៀមរាប | ៧៦៧ | ២.៦៩១ | ១.៣៤២ | ២៨៩ | ១២.៨៧៣ | ៧.៦៨៣ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៤៧១ | ៣៩.២៤០ | ២១.១៣៧ | ៣៨១ | ១៧.០៩៩ | ៩.៦៩៤ |
| ៧ | ខេត្តកំពង់ចាម | ៩៧៣ | ៥៤.៣៣៣ | ៣០.៧៥៥ | ១៣៩ | ៧.៦៧៧ | ៣.៨៦៧ |
| ៨ | ខេត្តព្រះសីហនុ | ២៦ | ១.២៣៧ | ៦០១ | ១៨ | ១.១៨៥ | ៥៥៦ |
| ៩ | ខេត្តព្រះវិហារ | | | | ១៥ | ៣.៤៩៥ | ១.៦៨៨ |
| ១០ | ខេត្តស្វាយរៀង | ១២ | ៤៨ | ៣៦ | ៣៤៤ | ១២.២៣៣ | ៦.៥៣៤ |
| ១១ | ខេត្តប៉ៃលិន | | | | | | |
| ១២ | ខេត្តកោះកុង | ០១ | ១២៥ | ៩៧ | ៤១ | ១.៤១៧ | ៦៦៥ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ១៦៧ | ៧.៨៩៤ | ៣.៨៥៧ | ០៧ | ២០១ | ១៥៧ |
| ១៦ | ខេត្តក្រចេះ | | | | | | |
| ១៧ | ខេត្តកែប | | | | ១៩ | ៣.៧៣៩ | ១.៨៤៣ |
| ១៨ | ខេត្តកំពង់ស្ពឺ | ០៨ | ៦៧៥ | ៣៤៤ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | | | | ០១ | ៧៤ | ៤៤ |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ២.៩៤៦ លើក | ១៣៥.៦៩២ នាក់ | ៨៣.៤២៧ នាក់ | ២.៤៥០ លើក | ១២៤.៧៣៧ នាក់ | ៦៧.៦៥៩នាក់ |
| | សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន ៥៤.៩៧២ លើក | | ចំនួនមនុស្សសរុប ២៧០.៧៤៨ នាក់ | | ចំនួនស្ត្រី ១១៥.៨០២ នាក់ | |

Rotha 81
h

**ខ.១.២.ការផ្សព្វផ្សាយតាមរយៈឧបករណ៍ ប្រព័ន្ធផ្សព្វផ្សាយ និងការចូលរួមជាវាគ្មិន**

**ខ.១.២.១.ការផ្សព្វផ្សាយតាមរយៈឧបករណ៍ផ្សព្វផ្សាយ និងតាមប្រព័ន្ធផ្សព្វផ្សាយ**

• **ថ្នាក់ក្រោមជាតិ**

- **ខេត្តកោះកុង៖** បានចាក់ផ្សាយកម្មវិធីកិច្ចពិភាក្សាស្តីពី ជម្រើសដោយសុវត្ថិភាព តាមរយៈវិទ្យុសាគរកោះកុង នៃមន្ទីរព័ត៌មានខេត្ត ក្នុងនោះរួមមាន ៖ ការជួញដូរមនុស្ស ចំនួន **១.២០០**លើក ការចំណាកស្រុកដោយសុវត្ថិភាព និងដោយប្រថុយប្រថាន ចំនួន **១៥០**លើក។
- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មានខេត្ត បានសហការជាមួយអង្គភាពជុំវិញខេត្ត បានផ្សាយផ្ទាល់តាមវិទ្យុFMជាតិនគរភ្នំ អំពីអំពើហិង្សាក្នុងគ្រួសារ និងការធ្វើចំណាកស្រុកដោយមិនស្របច្បាប់ និងស្តុតអប់រំ ជាពិសេសគឺការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិលក្នុងខេត្ត និងបានចាក់ផ្សាយឡើងវិញនៅវិទ្យុFMជាតិនគរភ្នំ១០៣MHZ ទូរទស្សន៍ជាតិខេត្តសៀមរាប( ទូរទស្សន៍ខ្សែកាបអង្គរ ខេត្តសៀមរាប ប៉ុស្តិ៍លេខ៩៥) និងតាមប្រព័ន្ធអនឡាញសរុបបានចំនួន **៧១០**លើក។

**ខ.១.២.២.ការចូលរួមជាវាគ្មិន**

• **ថ្នាក់ក្រោមជាតិ**

- **ខេត្តសៀមរាប៖** បានចូលរួមជាវាគ្មិននៅប៉ុស្តិ៍វិទ្យុជាតិនគរភ្នំ FM ១០៣ MHZ ស្តីពីការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០១លើក។
- **ខេត្តក្រចេះ៖** បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារ ក្រោមប្រធានបទ អំពើហិង្សា និងការរំលោភសេពសន្ថវៈលើស្ត្រី និងក្មេង តាមរយៈការផ្សាយសម្លេង និងការផ្សាយផ្ទាល់តាមគេហទំព័រហ្វេសប៊ុករបស់វិទ្យុសម្លេងស្ត្រីខេត្តក្រចេះបានចំនួន ០១លើក។

## ខ.២. ការបង្ការ ទប់ស្កាត់ តាមរយៈវិធានការជំនាញ

### ខ.២.១.វិធានការជំនាញទប់ស្កាត់ការធ្វើទេសន្តរប្រវេសន៍ (ចំណាកស្រុក)

**ខ.២.១.១.ការគ្រប់គ្រងជនបរទេស**

▪ **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

១. <u>ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់៖</u> ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន ៨៤លើក មនុស្សចំនួន ១៥២នាក់ មាន ៣៩សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ ៖

- ប្រកាសក្រសួងមហាផ្ទៃ ចំនួន៤៣លើក មនុស្សចំនួន ៩១នាក់(ស្រី១៤នាក់) មាន១៩សញ្ជាតិ
- បដិសេធមិនឲ្យចូលប្រទេស តាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ ចំនួន ៤១លើក មនុស្សចំនួន ៦១នាក់ ២០សញ្ជាតិ។

២. <u>ករណីស្នាក់នៅខុសច្បាប់</u>

- គ្មានឯកសារគ្រប់គ្រាន់ ០៣លើក មនុស្ស ០៣នាក់ មាន ០៣សញ្ជាតិ ស៊ុយអែត អាល្លឺម៉ង់ និងក្រូអាត
- ស្នាក់នៅលើសទិដ្ឋាការ ០១លើក មនុស្ស ០១នាក់ សញ្ជាតិប៉ាគីស្ថាន
- ប្រើប្រាស់លិខិតឆ្លងដែនក្លែងក្លាយ ០២លើក មនុស្សចំនួន ០២នាក់ សញ្ជាតិចិន និងឡាវ។

៣. <u>ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី</u>

- ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេសបែបអន្តោប្រវេសន៍ សរុបចំនួន ៥០គ្រួសារ មនុស្សចំនួន ៦៣នាក់ (ស្រី ៣៤នាក់) សញ្ជាតិវៀតណាម ក្នុងនោះដកហូតឯកសារ បានចំនួន ៥០ឯកសារ។

#### ខ.២.១.២.ការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស ក្នុងខែមករា នេះ សរុបចំនួន **៣៧១.៥៤៧**នាក់ (ស្រី**១៦១.៧២៣**នាក់) អនីតិជន**៩.៣៥៦**នាក់ (ស្រី**៣.៥៣២**នាក់) ក្នុងនោះ ស្របច្បាប់ចំនួន **២១០.០៨៥**នាក់ (ស្រី **៩៥.៣៩០**នាក់) អនីតិជន **៦៥៤**នាក់ (ស្រី **២៧៧**នាក់) មិនស្របច្បាប់ចំនួន **១៦១.៤៦២**នាក់ (ស្រី **៦៥.៨៣៣**នាក់) អនីតិជន **៨.៧០២**នាក់ (ស្រី **៣.២៥៥**នាក់) បើប្រៀបធៀបខែធ្នូ ឆ្នាំ២០១៨ មានការកើនចំនួន **៦៤**នាក់ ស្មើ **0,0១៧%**។

- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ចំនួន **៣៣**លើក។

#### ខ.២.២.វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សក្នុងគោលដៅចំពីសេវាកម្មផ្លូវភេទ

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ធ្វើបច្ចុប្បន្នភាពគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទទូទាំងរាជធានី-ខេត្ត សរុបចំនួន **៧៥**គោលដៅ ក្នុងនោះគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន **៦៦**គោលដៅ ។
- ស្នងការដ្ឋាននគរបាលខេត្ត តាកែវ មណ្ឌលគីរី ស្វាយរៀង សៀមរាប កែប ឧត្តរមានជ័យ បន្ទាយមានជ័យ ក្រចេះ និងរតនគីរី បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីក្នុងហាងម៉ាស្សាខារ៉ាអូខេបានចំនួន **៥៦៣**គោលដៅ និងមានមនុស្សចំនួន **២.២៤២**នាក់ (ស្រី**១.៧៩៧**នាក់)។
- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ព្រះវិហារ ក្រចេះ ស្ទឹងត្រែង និងព្រៃវែង បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន **៣៥**លើក។

#### ខ.២.៣.ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

▪ ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តច្បាប់**) នៃច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន **២០៨**គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងបានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ចំនួន ០៦នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

### ខ.៣. កិច្ចការពារកុមារ

• ថ្នាក់ក្រោមជាតិ

- **ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ** សហការជាមួយអង្គការម្លប់តាប៉ាង ដើម្បីការពារសុវត្ថិភាពកុមារ បានដាក់បណ្ដាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្ដាញតាមសហគមន៍ និង ផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន **១.១៣៣**នាក់។

- **ស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន** បានចាត់កម្លាំងជំនាញចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមកាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋានចំនួន ៨០កន្លែង។
- **ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង** សហការជាមួយប៉ុស្តិ៍នគរបាលរដ្ឋបាលចុះស្រង់ទិន្នន័យ តាមគោលដៅរោងចក្រ សហគ្រាស សិប្បកម្ម សង្ស័យអាចពាក់ព័ន្ធការកេងប្រវ័ញ្ចពលកម្មកុមារ ចំនួន ០១លើក ស្មើនឹង ០២គោលដៅ។

## ខ.៤. ការលើកកម្ពស់ជីវភាព

- ថ្នាក់ក្រោមជាតិ
  - **ស្នងការដ្ឋាននគរបាលខេត្តសៀមរាប និងអង្គការសេជាក** សហការជាមួយអាជ្ញាធរមូលដ្ឋាន ផ្សព្វផ្សាយ កសិករឲ្យយល់ដឹងអំពីការជួញដូរមនុស្ស ការជួញដូរកម្លាំងពលកម្ម និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបណ្តុះបណ្តាលការងារធ្វើកសិកម្មធម្មជាតិជាលក្ខណៈគ្រួសារ នៅក្នុងស្រុកគោលដៅចំនួន០៧ (ស្រុកស្រីស្នំ វ៉ារិន សូទ្រនិគម ជីក្រែង អង្គរជុំ និងស្រុកពួក) មាន១១ឃុំ និង ៦១ភូមិ សរុបបាន ១០លើក អ្នកចូលរួម ៤៣នាក់(ស្រី ៣១នាក់)។

## ខ.៥. ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការផ្តល់ប័ណ្ណព្រំដែនដល់ជនមុខសញ្ញាងាយរងគ្រោះ

- ថ្នាក់ក្រោមជាតិ
  - រដ្ឋបាលខេត្តចំនួន០៣ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ៨.២២៦ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មាន:
    - ខេត្តបាត់ដំបង ចំនួន ៥.២២០ប័ណ្ណ
    - ខេត្តបន្ទាយមានជ័យ ចំនួន ២.៣២១ប័ណ្ណ
    - ខេត្តប៉ៃលិន ចំនួន ៦៨៥ប័ណ្ណ។

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## គ.១. ការងារអនុវត្តច្បាប់

### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តច្បាប់**) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន **១៤/១៤**ករណី (បើប្រៀបធៀបនឹងខែមុនស្មើគ្នា) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **១៦**នាក់(ស្រី **០៣**នាក់ ជនសង្ស័យជាជនបរទេស **០១**នាក់)។ សង្គ្រោះជនរងគ្រោះ ចំនួន **៧៤**នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ **១៤**នាក់ អាយុ១៥-១៧ឆ្នាំ **១៥**នាក់ និងអាយុ១៨ឆ្នាំឡើង **៤៥**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច **០៧**នាក់ និងប្រគល់ទៅគ្រួសារ **៦៧**នាក់) ក្នុងនោះមាន៖

#### គ.១.១.១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន **០៣/០២ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន **០៥**នាក់(ស្រី **០៣**នាក់) ។ សង្គ្រោះជនរងគ្រោះចំនួន **៥៥**នាក់ អាយុ-១៥ឆ្នាំ **០៦**នាក់ អាយុ១៥-១៧ឆ្នាំ **១១**នាក់ និង អាយុ១៨ឆ្នាំឡើង៣៨នាក់ (ប្រគល់ឲ្យសង្គមកិច្ច **០៧**នាក់ និងឲ្យគ្រួសារ**៦៧**នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់<br>-ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០១<br>០២ | ០២<br>៥៣ | ០១<br>០៤ |
| *សរុប* | *០៣ ករណី* | *៥៥ នាក់* | *០៥ នាក់* |

**គ.១.១.២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ១១/១២ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១១នាក់ ជនបរទេស ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៩នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ ០៨នាក់ អាយុ១៥-១៧ឆ្នាំ ០៤នាក់ អាយុ១៨ឆ្នាំឡើង ០៧នាក់ (ប្រគល់ទៅសង្គមកិច្ច ០៧នាក់ និងប្រគល់ទៅគ្រួសារ ១២នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -សញ្ចារកម្ម | ០១ | ០៤ | ០១ | ចិន ១ |
| -សញ្ចារកម្ម(មានអនីតិជន) | ០១ | ០២ | ០១ | |
| -សញ្ចារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ) | ០១ | ០៥ | ០១ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥ | ០៥ | |
| -អំពើអាសប្រាថាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | ០៣ | |
| *សរុប* | *១១ ករណី* | *១៩ នាក់* | *១១ នាក់* | *០១ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងការទទួលសាកសព

**ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់**

- **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

  យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ មានចំនួន ១១នាក់ (ស្រី ១០នាក់) ក្នុងនោះមកពី៖

  - ប្រទេសចិន ចំនួន ០៩នាក់ (ស្រី ០៩នាក់)
  - ប្រទេសម៉ាឡេស៊ី ចំនួន ០២នាក់ (ស្រី ០១នាក់)។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

  ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាសរុបចំនួន ស្ត្រី១៤នាក់(កុមារី០១នាក់) ក្នុងនោះមាន ៖

  - **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ ចំនួន ០១នាក់(កុមារី)។

- **ក្រុមការងារការពារជនរងគ្រោះ** នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ អង្គការរតនៈអន្តរជាតិ អង្គការសួននៃក្តីសង្ឃឹមនៃកម្ពុជា និងអង្គការមេត្រីអន្តរជាតិ បានទទួលស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន ១៣នាក់ រួមមានមកពី៖ ប្រទេសចិន ០៩នាក់ វៀតណាម ០៣នាក់ ម៉ាឡេស៊ី ០១នាក់ ក្នុងនោះមានករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ១២នាក់ និងជួញដូរកម្លាំងពលកម្ម ០១នាក់។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួលពលករខ្មែររងគ្រោះដែលត្រឡប់ពីបណ្តាប្រទេសផ្សេងៗសរុបចំនួន ១៤នាក់ (ស្រី) ក្នុងនោះ៖ មកពីប្រទេសចិន១៣នាក់ និងប្រទេសម៉ាឡេស៊ី ០១នាក់ តាមការសម្ភាសបានឲ្យដឹងថា អ្នកទាំងនោះទៅតាមរយៈមេខ្យល់។

▪ **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ៩០លើក មនុស្សចំនួន ១.១២០នាក់ (ស្រី ៣៦៩នាក់ កុមារ ១២០នាក់)។ ក្នុងនោះតាម៖

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន ៩៥នាក់ (ស្រី ៣០នាក់)
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន ១.០២២នាក់ (ស្រី ៣៣៩នាក់) កុមារ១២០នាក់
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន ០២នាក់
- និងមកពីប្រទេសឡាវ ចំនួន ០១នាក់។

• **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

**ស្នងការដ្ឋាននគរបាលខេត្ត** ចំនួន៣ បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាត់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ សរុបចំនួន ១.១៩២នាក់ (ស្រី ៤០២នាក់ អនីតិជន ១៤៤នាក់) ក្នុងនោះមាន៖

- ខេត្តបន្ទាយមានជ័យ ចំនួន ១.១៣១នាក់ (ស្រី ៣៨៨នាក់) អនីតិជន ១៤៤នាក់
- ខេត្តបាត់ដំបង ចំនួន ៥០នាក់ (ស្រី ១២នាក់)
- ខេត្តកោះកុង ចំនួន ១១នាក់ (ស្រី ០២នាក់)។

**ឃ.១.២.ការទទួលសាកសពបញ្ជូនត្រឡប់**

▪ **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

សាកសពពលរដ្ឋខ្មែរដែលបានស្លាប់ដោយសារគ្រោះថ្នាក់ផ្សេងៗ បានបញ្ជូនត្រឡប់តាមច្រកទ្វារអន្តរជាតិ សរុបចំនួន ០៩សព(ស្រី ០១) ក្នុងខេត្តបន្ទាយមានជ័យ ចំនួន ០៤សព(ស្រី ០១) និងខេត្តបាត់ដំបង ចំនួន ០៥សព។

## ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា ចំនួន ៣១នាក់(ស្ត្រី ២៤នាក់ កុមារ ០៥នាក់) រួមមាន៖

- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានផ្តល់សេវាស្នាក់នៅរយៈពេលខ្លី និងស្តារនីតិសម្បទាដល់ជនរងគ្រោះ និងងាយរងគ្រោះ ចំនួន ០៨នាក់ (ស្ត្រី ០១នាក់ កុមារ ០៥នាក់) និងបានបញ្ជូនទៅអង្គការតំណក់ទឹក អង្គការគ្រួសារថ្មី អង្គការក្តីសង្ឃឹមនិងយុត្តិធម៌ ដើម្បីទទួលសេវាអប់រំក្នុង និងក្រៅប្រព័ន្ធ និងសេវាផ្សេងៗ ទៀតមុនពេលធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះវិញ។
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ បានផ្តល់សេវា និងប្រឹក្សាយោបល់រួចបញ្ជូនស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ២៣នាក់ ទៅទទួលសេវាបន្តនៅអង្គការដៃគូ។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មស្ត្រីរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សឲ្យទៅតាមសហគមន៍វិញ សរុបចំនួន ០៤នាក់(ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ០២នាក់ និងករណីរំលោភសេពសន្ថវៈ ០២នាក់)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការបណ្តុះបណ្តាល

ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

- ថ្នាក់ក្រោមជាតិ
  - ខេត្តស្វាយរៀង

លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត សហការជាមួយអង្គការឆាលហ្វាន់បើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរកុមារ ចំនួន ០១វគ្គ មានសិក្ខាកាមចូលរួម ៣៦នាក់ (ស្រី១១នាក់)។

#### ក.២. សិក្ខាសាលា

ក.២.១.សិក្ខាសាលាក្នុងប្រទេស

- ថ្នាក់ជាតិ
  - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ចំនួន ០១វគ្គ សិក្ខាកាមចូលរួម ១២១នាក់(ស្រី ៤៥នាក់) នៅសណ្ឋាគារកាំបូឌីយ៉ាណា ក្រោមការឧបត្ថម្ភរបស់អង្គការយូនីសេហ្វ។

ក.២.២.សិក្ខាសាលាក្រៅប្រទេស

- ថ្នាក់ជាតិ
  - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

បានចាត់មន្ត្រីជំនាញទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់មេគង្គ លើកទី០៩ ស្តីពីសំណាញ់ឯកភាពឆ្ពោះទៅមុខនៃការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។

## ខ. កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

➢ **កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈជាតិ**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ **បានដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុង៖**
    - ស្តីពីការកែសម្រួលខ្លឹមសាររបាយការណ៍ប្រចាំឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
    - ស្តីពីការផ្តល់យោបល់លើជាតុចូលសំណើសុំរៀបចំគម្រោងកម្មវិធី សេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ សេចក្តីព្រាងវិសោធនកម្មច្បាប់។
    - ស្តីពីសេចក្តីព្រាងទម្រង់ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០១៩-២០២៣) របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា។

    **បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង៖**
    - ពិនិត្យសេចក្តីព្រាងច្បាប់ "**ពពោះជំនួស**" ដែលមានអ្នកចូលរួមចំនួន **២០**នាក់ (**ស្រី០៣**នាក់) សាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

  បានរៀបចំកិច្ចប្រជុំ ស្តីពីការធ្វើបច្ចុប្បន្នភាពទម្រង់ទទួល តាមដាន និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាមួយអង្គការដៃគូ និងមន្ត្រីជំនាញបច្ចេកទេស ចំនួន **០២**លើក។

➢ **កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈអន្តរជាតិ**

- **ខេត្តព្រះវិហារ**

  រដ្ឋបាលខេត្ត និងសមត្ថកិច្ចច្រកទ្វារព្រំដែនតំបន់អានសេះ បានជួបប្រជុំជាមួយភាគីថៃ ស្តីពីកិច្ចសហប្រតិបត្តិការការពារសន្តិសុខតាមបណ្តោយព្រំដែន និងបញ្ហាពលករធ្វើចំណាកស្រុកដោយប្រថុយប្រថានដើម្បីស្វែងការងារធ្វើក្រៅប្រទេស និងពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្លងដែនខុសច្បាប់ ចំនួន០១លើក មនុស្សចូលរួមចំនួន **៣៨**នាក់ នៅខេត្តព្រះវិហារ។

### ខ.២. ទស្សនកិច្ចសិក្សា

- **ថ្នាក់ជាតិ**
  - **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

    លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចុះទស្សនកិច្ចការងារដល់ទីតាំងទទួលពលករ និងបានជួបប្រជុំពិភាក្សាការងារដើម្បីពង្រឹងកិច្ចសហការ រវាងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងអង្គការដៃគូក្នុងការងារទទួល និងផ្តល់សេវា ដល់ពលករបញ្ជូនត្រលប់ និងផ្តល់កិត្តិយសប្រគល់លិខិតថ្លែងអំណរគុណ របស់គណៈកម្មាធិការជាតិ ដល់តំណាងក្រុមហ៊ុន **សុខ ស្រេង** ដែលបានផ្តល់ទីតាំងក្នុងការបំពេញការងារ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៩ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

### ខ.៣. ការទទួលជួបពិភាក្សាការងារ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

  លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានជួបពិភាក្សាការងារជាមួយអង្គការ Terre Des Hommes ពីដំណើរការនីតិវិធីស្នើសុំបន្តការគាំទ្រ ពីគ.ជ.ប.ជ និងការបន្តកិច្ចព្រមព្រៀងអនុស្សរណៈនៃការយោគយល់គ្នារវាងគ.ជ.ប.ជ និងអង្គការ Terre Des Hommes នៅបន្ទាប់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍។

**ខ.៤. ការងារសម្របសម្រួល**

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ១៩លើក មានអ្នកចូលរួមសរុប ៣៧១នាក់ (ស្រី ៨៧នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១៣លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ជាសមាជិក គ.ជ.ប.ជ ០១លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ០៥លើក។ (**ឧបសម្ព័ន្ធ**)

## III. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គម។

## IV. ទិសដៅខែកុម្ភៈ ឆ្នាំ ២០១៩

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ **"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី"** (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.................ខែ..........ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៩

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

## ការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ១៩លើក) មនុស្សចំនួន ៣៧១នាក់ (ស្រី ៨៧នាក់)

| **ស្ថាប័ន សម្របសម្រួល** | **សកម្មភាព** |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | សម្របសម្រួលចំនួន ១៣លើក<br>▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ៖<br>- បានអញ្ជើញចូលរួមបើក និងបិទវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារពីការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរកុមារវគ្គ២ ក្រោមកិច្ចសហការជាមួយ អង្គការ Child Fund នៅសាលាខេត្តស្វាយរៀង។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ៖<br>- បានអញ្ជើញចូលរួមបិទវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារក្នុងការធ្វើចំណាកស្រុកហើយគ្មានសុវត្ថិភាព និងការជួញដូរកុមារ ក្រោមអធិបតីភាព **លោកជំទាវ** អនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ. នៅសាលាខេត្តស្វាយរៀង។<br>- បានអញ្ជើញចូលរួមប្រជុំ ស្តីពីការរៀបចំសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ អគារទ។<br>- បានអញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈរវាងក្រសួងមហាផ្ទៃ និងអង្គការ IJM ក្រោមអធិបតីភាព ឯកឧត្តម សន្តិបណ្ឌិត **តេង សាវង្ស** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ អគារទ។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់៖**<br>- មន្ត្រីក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ចំនួន ០២រូប បានចូលរួមក្នុងកម្មវិធីអប់រំផ្សព្វផ្សាយរបស់ក្រុមការងារកាយឫទ្ធិស្ត្រីកម្ពុជា ដែលដឹកនាំដោយលោកជំទាវ **ស៊ិន សិរី** អគ្គស្នងការកាយឫទ្ធិស្ត្រីកម្ពុជា និងមានការសហការចូលរួមពីក្រសួងកិច្ចការនារី បានផ្សព្វផ្សាយពីស្ថានភាពទូទៅនៃអំពើជួញដូរមនុស្ស ដែលផ្តោតសំខាន់លើបទល្មើសស៊ីឈ្នួលពពោះជំនួស ដល់លោកមេឃុំ នាយិកា អ្នកគ្រូ សិស្សានុសិស្សសាលាសង្គម និងមាតាបិតាសិស្ស សរុបចំនួន ៨៥នាក់ (ស្រី ១៤នាក់ សិស្សស្រី ៧១នាក់)។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ៖**<br>- ក្រុមទំនួយកិច្ចការការពារជនរងគ្រោះ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមេត្រីអន្តរជាតិ ចុះសួរសុខទុក្ខស្ត្រីរកស៊ីពពោះជំនួយ មានទីលំនៅខេត្តកណ្តាល ដែលបានសម្រាលកូនប្រុសអាយុទើបតែ២ខែ។<br>▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌៖**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម វិរៈ** បានអញ្ជើញចូលរួមកិច្ចប្រជុំ៖ |

○ ត្រៀមដើម្បីចូលរួមធ្វើបទបង្ហាញ និងពិភាក្សាការងារក្នុងក្របខណ្ឌក្រសួង មហាផ្ទៃ ជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ នៅក្រសួងមហាផ្ទៃ អគារV។

○ ស្តីពីការចូលរួមធ្វើបទបង្ហាញ និងពិភាក្សាការងារក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ ជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ នៅទីស្តីការនាយករដ្ឋមន្ត្រី (វិមានសន្តិភាព)។

▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**

- លោកជំទាវ ឧត្តមសេនីយ៍ត្រី **វ៉ន សិរីលក្ខិណា** បានដឹកនាំកិច្ចប្រជុំស្តីពី ការពិភាក្សា និងរៀបចំកម្មវិធី និងធ្វើគម្រោងចំណាយផ្សេងៗ សម្រាប់ធ្វើបទបង្ហាញទាក់ទងនឹងការប្រើប្រាស់ប្រព័ន្ធប្រមូលព័ត៌មាន ដៃគូអភិវឌ្ឍន៍លើសេវាកម្មសម្រាប់ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយមានការចូលរួមពីតំណាងអង្គការចាប់ដៃ និងអង្គការវីនរ៉ក ប្រចាំកម្ពុជា។
- ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះទៅបំពេញបេសសកម្មនៅទីក្រុងប៉ោយប៉ែត ដើម្បីធ្វើការសិក្សាពីតម្រូវការបច្ចេកទេសផ្នែកព័ត៌មានវិទ្យា សម្រាប់កសាងប្រព័ន្ធ Database នៅមណ្ឌលសំចតសម្រាប់ទទួលពលករ។

▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍៖**

- លោកអនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាគម្រោង ស្តីពីការរៀបចំផែនការ ការងាររបស់កម្មវិធីត្រីកោណក្នុងតំបន់អាស៊ាន សម្រាប់ឆ្នាំ២០១៩ និងការត្រួតពិនិត្យវឌ្ឍនភាព ឆ្នាំ២០១៨ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។

▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- លិខិតរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ លិខិតចេញ ចំនួន **១០**ច្បាប់ និងលិខិតចូល ចំនួន **១០**ច្បាប់។
- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ចំនួន **១៥**ច្បាប់ លិខិតចូល ចំនួន **២៣**ច្បាប់។
- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្តទាំង២៥ និងបូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ និងរបាយការណ៍ឆ្នាំរបស់ គ.ជ.ប.ជ។
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។
- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី(wiki)។
- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។
- ស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា convert ជា PDF បានចំនួន ៧០ច្បាប់ និងបានចងក្រងជាសៀវភៅដាក់ជូនលោកជំទាវរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកជំទាវឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។
- បោះពុម្ពសៀវភៅភ្នាក់ងារជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ ពលការិនី ទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស ដាក់ជូនលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ និងលោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ។
- Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធវីគី(wiki) បានចំនួន **១៦**ច្បាប់។

| | |
|---|---|
| | - អាប់ឡូតរូបភាពសកម្មភាពចូលក្នុងប្រព័ន្ធអ៊ីនធើណេតក្នុងបណ្ណាល័យវីគី( wiki)គ.ជ.ប.ជ បានចំនួន **៣៦**សកម្មភាព។<br>- អាប់ឡូតព័ត៌មានចូលគេហទំព័រ គ.ជ.ប.ជ ធ្វើលិខិតថ្លែងអំណរគុណជូនដល់អង្គការ ក្រុមហ៊ុន ស្ថាប័នរដ្ឋ ស្ថានីយ៍ទូរទស្សន៍ តារាចម្រៀង ដែលបានចូលរួមសហការរៀបចំទិវាជាតិ ១២ធ្នូ ខួបលើកទី១២ ឆ្នាំ២០១៨។<br>- ត្រួតពិនិត្យ និងកែសម្រួលលើបញ្ហាខ្វះខាតក្នុងការបញ្ចូលរូបភាពទៅក្នុងវេបសាយ។<br>- កែសម្រួលលើមាតិកាក្នុង Project: terms.ncct.gov.kh និងបកប្រែខ្លឹមសារនៅក្នុង keyword ដែលអង្គការវីនរ៉ក់ផ្តល់អោយ និងដាក់ Keyword ទៅក្នុងវីគី( wiki ) terms.ncct.gov.kh សម្រាប់ផ្តល់ភាពងាយស្រួលទាញយកមកប្រើប្រាស់ពេលក្រោយ។<br>- ដោះស្រាយបញ្ហា Error មួយចំនួននៅក្នុង terms.ncct.gov.kh និងត្រួតពិនិត្យមើលការងារទូទៅនៅក្នុង wiki.ncct.gov.kh។<br>- រៀបចំ MOU របស់ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ។<br>- ចុះបេសកម្មទៅកាន់ក្រុងប៉ោយប៉ែតដើម្បីធ្វើការសិក្សាពីតម្រូវការផ្នែកព័ត៌មានវិទ្យាសម្រាប់កសាងប្រព័ន្ធ Database នៅមណ្ឌលសំចត សម្រាប់គ្រប់គ្រងព័ត៌មាន លំហូរទេសន្តរប្រវេសន៍។ |
| **អន្តរក្រសួង ស្ថាប័ន សម្របសម្រួលចំនួន ០១លើក មនុស្ស ៣០នាក់ (ស្រី ០៨នាក់)** | |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - បានចាត់គ្រូឧទ្ទេសចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកណ្តាល រៀបចំដោយអង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា អ្នកចូលរួមចំនួន ៣០នាក់ ស្រី ០៨នាក់។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ០៥លើក អ្នកចូលរួមសរុបចំនួន ២៤១នាក់ (ស្រី ៧៩នាក់)** | |
| **ខេត្តព្រះសីហនុ** | - លោកជំទាវ អភិបាលរង និងជាលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងទិសដៅ២០១៩ មានសមាសភាព ចូលរួមចំនួន ៥៣នាក់ ស្រី ២៣នាក់។ |
| **ខេត្តតាកែវ** | - លោកស្រី គា សុភ្ញ អភិបាលរងខេត្តបានដឹកនាំសម្របសម្រួលកិច្ចប្រជុំជាមួយក្រុមការងារនៅស្រុកសំរោងស្តីពីការពង្រឹងការងារជួញដូរមនុស្ស និងការរំលោភផ្លូវភេទ ០១លើក មនុស្ស ១៨៨នាក់ ស្រី ៥៦នាក់។ |
| **ខេត្តសៀមរាប** | - លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានអញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋបាលខេត្តសៀមរាប និងអង្គការហ្វ្រេនអ៊ីនធើណេសិនណល(កម្មវិធីកល្យាណមិត្ត) ផ្តោតលើការធ្វើសមាហរណកម្មកុមារ និងយុវវ័យចាប់ពីអាយុ ០ ដល់ ២៤ឆ្នាំ នៅសាលាខេត្ត ០១លើក។ |
| **ខេត្តឧត្តរមានជ័យ** | - ចាត់មន្ត្រីជំនាញចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពីមូលដ្ឋានគ្រឹះជំនាញសង្គមក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច នៅសណ្ឋាគារប្រេស៊ីដង់ ខេត្តបាត់ដំបង។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំប្រចាំខែមករា ឆ្នាំ២០១៩ ដែលមានសមាសភាពក្រុមទាំង៦ និងបណ្តាស្រុកទាំង៨។ |